# រឿងព្រេងទាក់ទងនិងពិធីបញ្ចូលម្លប់កូនស្រី

មានរឿងដំណាលថា កាលនោះមានមហាចោរម្នាក់ពុំមានភរិយា បានសង់ផ្ទះមួយខ្នងយ៉ាងល្អផ្កាច់នៅក្នុង ព្រៃស្ងាត់ ដើម្បីនឹងទុកដាក់របស់ទ្រព្យមាន មាស ប្រាក់ សំពត់ អាវសារសៃ្បជាដើមដែលខ្លួន ទៅលួចប្លន់គេបានពីទីផ្សេងៗមក មហាចោរនោះលុះកាលជាចំណោរក្រោយមក ក៏រំពឹងគិតថា "អាត្មាអញមានទ្រព្យសម្បត្តិច្រើនដល់ម្លឹងដែរហើយ តែទាស់ត្រង់គ្មានអ្នកណាថែរក្សា គិតសព្វគ្រប់ទៅការខំប្រឹងរបស់អញនេះ ដូចជាគ្មានបានការអ្វីសោះ ! ព្រោះថាបើកាលណាអាត្មាអញស្លាប់ទៅ ទ្រព្យអស់ទាំងនេះនិងក្លាយទៅជារបស់អសារឥតការ គួរឱ្យស្តាយបើមានកូនប្រពន្ធគ្រាន់និងស៊ីមរតកនោះទៅវ៉ា អាត្មាអញនិងមិនសូវជាស្តាយ ពេក" ។

គិតហើយមហាចោរក៏ដើរទៅក្រវែលភូមិអ្នកស្រុក រំពៃគយគន់មើលក្មេងស្រី-ប្រុស ដែលនាំគ្នាលេងខ្សែវខ្វានៅក្រោមម្លប់ឈើ ។ លុះគយគន់ទៅឃើញនាងតូចមួយនោះ មានរូបឆោមស្អាតសមរម្យ មានសាច់ឈាមថ្លា ផ្ទៃថ្ងូរ គួរឱ្យស្រលាញ់ ក៏និយាយលួងលោមកូននោះឱ្យបែកចេញពីហ្វូង ហើយក៏បញ្ឆោតនាំយកទោដល់ផ្ទះផងខ្លួន ។ ដោយខ្លាចកូនក្មេងនោះលួចរត់ទៅរកម៉ែឪវ៉ាវិញ ព្រមទាំងការពារកុំឱ្យម្តាយឪពុកវាតាមទៅរកឃើញ មហាចោរក៏យកក្មេងនោះទៅលាក់ទុកក្នុងបន្ទប់ចាក់សោយ៉ាងខ្ជាប់ខ្ជួន ។ រាល់ពេលបាយ ឬ ពេលបានចំណីអាហារឆ្ងាញ់មក មហាចោរតែងហុចតាមបង្អួចមួយ តូចទៅឱ្យនាងបរិភោគ ។

ក្មេងស្រីនោះនៅក្នុងម្លប់ ក៏ចេះតែចំរើនសាច់ឈាមរាល់ថ្ងៃជាលំដាប់ ។ លុះនាងពេញវ័យក្រមុំការដែល នាងមិនមានត្រូវពន្លឺព្រះអាទិត្យ និងមិនបានជាន់ដីបណ្តាលឱ្យនាងមានជំងឺស្គមស្គាំងស្លេកស្លាំង ។ មហាចោរ ភ័យណាស់មិនដឹងជាកូនមានជំងឺអ្វី ក៏ត្រាច់ទៅក្នុងភូមិមួយឆ្ងាយទើបបានជួបនិងដូនចាស់ម្នាក់ ធ្លាប់ធ្វើឆ្មប ក៏និយាយអង្វរសុំអញ្ជើញដូនឱ្យមកជួយមើលកូនខ្លួន ។

យាយម៉បនោះមកដល់ ចូលទៅសួរសុខទុក្ខនាងហើយយល់ការណ៍ ក៏ប្រាប់នាងថា "ចៅយាយអើយ! ចូរចៅកុំព្រួយអ្វី! ចៅឈឺនេះគ្មានអ្វីក្រៅពីជំងឺគ្រប់ការទេ គឺពេលដែលនាងផ្លាស់វ័យនេះឯងហើយ ដែលធ្វើឱ្យនាងចេះតែរសាប់រសល់ចុកខ្នង ចុកចង្កេះ ល្វិតល្វៃ ទន់ដៃទន់ជើង កុំព្រួយអ្វីណាចៅ ! ចាំយាយផ្សំថ្នាំសង្កូវឱ្យនាងញ៉ាំឱ្យបានធូរស្រាលឆាប់រហ័ស" ។ ថាហើយ យាយម៉បក៏ទៅរកស្មោះសំបកឈើមកផ្សំថ្នាំដាំឱ្យនាងនោះអាស្រ័យ ហើយផ្តាំថា "ចៅអើយ! ចៅយកថ្នាំនេះទៅហាលថ្ងៃឱ្យស្ងួត ហើយរកថូ ឬ ផ្តាំងអ្វីដាក់ទុកទៅ ពេលនាងដឹងថា ជិតដល់រដូវកាលហើយចូរនាងយកមួយកញ្ចប់ មកដាំញ៉ាំ៤-៥ថ្ងៃទៅ នោះនាងនឹងបានធូរស្រាលក្នុងខ្លួនដូចបំណង ហើយសាច់ឈាមពណ៌សម្បុររបស់នាងក៏រឹតតែល្អឡើងដែរ " ។

លុះកូនស្រីមហាចោរផឹកថ្នាំ បានធូរស្រាលស្បើយរោគហើយ យាយម៉បក៏ចូលទៅសំពះសុំលាមហាចោរត្រលប់ទៅមើលផ្ទះសំបែងវិញ ។ មហាចោរបានយកមាសប្រាក់ជូនជាទ្រនឹបរង្វាន់យាយម៉ប ហើយជូន ត្រឡប់ដល់ផ្ទះវិញ ។ ពេលរៀបចេញដំណើរពីផ្ទះមហាចោរទៅ យាយម៉បនឹកក្នុងចិត្តថា "កន្លែងមហាចោរនេះ ឆ្ងាយដាច់ ស្រយាល

ពីភូមិស្រុកគេណាស់ ឯព្រៃទៀតសោតក៏ញឹកស្វាត់ជ្រងំ គួរឱ្យខ្លាចប្រសិនបើអញត្រូវការចង់ មករកទីនេះវិញធ្វើម្ដេច និងរកផ្លូវមកឃើញ!" នឹកសព្វគ្រប់ហើយ គាត់ក៏រកបានគ្រប់ឪឡឹកមួយបង្វិច យកមកតាមខ្លួន ដើរបណ្ដើរចាប់គ្រាប់ឪឡឹករោយបណ្ដើរ រហូតមកដល់ផ្ទះគាត់។

តទៅនេះនិងថ្លែងចាប់សារដើមបន្តិច អំពីពេលដែលយាយម៉បបានទៅនៅថៃទាំងកូនចោរនោះមកគាត់តែងតែសង្កេតមើលឫកពារ និងរូបឆោមកូននោះឃើញល្អ ក៏ចេះតែគួចចិត្តទុកនិងសម្លឹងរកកម្លោះរូបណា មួយឱ្យសមគ្នានិងនាង ។ ថ្ងៃមួយអាស្រ័យបច្ច័យហេតុផលពីបុព្វបណ្ដាលចិត្តមាណពម្នាក់ ដែលត្រលប់ពីរៀនវិជ្ជាការឱ្យចង់ចូល ទៅសុំសំរាកនៅផ្ទះយាយម៉បនោះសិន ត្បិតថ្ងៃកាន់តែជ្រេ កម្លាំងក៏អស់ ហេវបាយ ផ្លូវទៅមុខក៏ឆ្ងាយ ក្រែងយប់កណ្ដាលផ្លូវ ក៏រូតរះចូលទៅសំពះដូនចាស់សុំសំណាក់មួយយប់ ។ ដូនចាស់កំពុងតែរៀបចំ និងដាំបាយបរិភោគ ជូនក្រឡេកឃើញមាណពចូលមកសំពះសុំស្នាក់ ក៏មានចិត្តសប្បុរសទទួលឱ្យនៅ ហើយដាំបាយបណ្ដើរ សំណេះសំណាល់សួរអំពី ពូជពង្សបណ្ដើរ។ លុះអាស្រ័យបាយរួច និងទុកដាក់ចានក្បានស្រេច យាយម៉ប ដែលចេះតែលបសង្កេតរូបឆោម មាណពនោះតាំងតែពីចូលមក ក៏បង្ហើបសំណួរថា "ចៅអើយ ! ពិកាលដែលចៅលាឪពុកម្ដាយមកស្វែងរកគ៏រិះវិជ្ជានេះតើឪពុកម្ដាយចៅមានស្ដីដណ្ដឹង កូនចៅអ្នកឯណាទុកឱ្យចៅហើយឬនៅ?" ។

ចៅមាណពតបថា "មិនទាន់មាននៅឡើយទេ! " ហើយបន្ដសម្ដីថា "ខ្ញុំនឹកថាប្រសិនបើនៅពេលដែលខ្ញុំធ្វើដំណើរកាត់ស្រុកភូមិគេនេះ បានជួបស្រីណាមួយមានលក្ខណៈសម្បត្តិសមរម្យល្អ ខ្ញុំនឹងយកគេធ្វើប្រពន្ធហើយ! តើលោកយាយមានបានស្គាល់កូនចៅលោកអ្នកណា ដែលល្អនៅក្នុងស្រុកភូមិរបស់យាយនេះ ដែរឬទេ?" ។

-ចៅអើយ! (យាយម៉បនោះឆ្លើយ) នៅក្នុងស្រុកភូមិនេះ មិនឃើញមានស្ត្រីណាម្នាក់ដែលសក្ដិសម និងចៅទេ ប៉ុន្តែជីដូនធ្លាប់បានឃើញស្ត្រីម្នាក់ដែរ នាងនោះជាកូនមហាចោរ នៅក្នុងព្រៃដាច់ស្រយាល ឯណោះ។

យាយម៉បក៏និយាយរាប់រៀបអំពើដំណើររឿងដែលគាត់បានទៅឃើញនាងនោះ និងបានសង្កេតឃើញឫកពារសមរម្យព្យពាក្យសរសើររបស់យាយម៉ប មាណពនោះអន្ទះសារចង់ឃើញរូបនាង ក៏អង្វរឱ្យយាយជូន ទៅ។

-ទេចៅ (យាយម៉បប្រកែក) យាយជូនទៅមិនបានទេ ព្រោះយាយខ្លាចមហាចោរនោះណាស់ ធម្មតា ចិត្តមហាចោរតែដល់មានការអ្វីស្រួលមិនស្រួលកើតឡើង វាមុខជាមកសម្លាប់យាយចោលហើយ ! ។ យាយចាស់ហើយ តែយាយនៅចង់រស់នៅឡើយ។ ចូរចៅជឿជាក់ថា យាយចង់ឱ្យចៅនិងនាងនោះបានគ្នាជាប្ដីប្រពន្ធណាស់ ព្រោះតាំងតែពីកាលយាយបានឃើញនាងមក ទោះពេលយាយចេញដើរទៅផ្សា ទៅកាន់ភូមិនានា ទៅសង្គ្រោះគេក្ដី យាយតែងតែគយគន់សម្លឹងមើលរាល់ថ្ងៃ តែមិនប្រទះឃើញ បុរសកម្លោះណាម្នាក់ ឱ្យសមល្មមនិងចិត្តយាយសោះ ទើបតែពេលនេះចៅមកដល់ចំជាមហាលាភហើយ ចៅគេងឱ្យស្រួលទៅ ប្រឹកស្អែកចាំចៅចេញដំណើរទៅរកនាង" ។ នៅពេលយប់នោះ បុរសចេះតែគិតសព្វគិតគ្រប់ ដេកក៏មិនលក់ ដោយប្លែកកន្លែងផង ទន្ទឹងឱ្យតែភ្លឺឆាប់ផង ណាមួយគិតបារម្ភ អំពីដំណើរក្នុងព្រៃតែម្នាក់ឯង ណាមួយគិតដល់គ្រោះថ្នាក់ជាមួយនិងមហាចោរ លុះយប់ យន់ទើបបុរសគេងលង់លក់ទៅ

ពេលមាន់រងាវភ្លឺស្រាង១ យាយម៉បក្រោកដាំបាយ រកម្ហូបក្រៀមក្រោះ ទឹកបំពង់ ទុកបំរុងជាស្បៀង ឱ្យមាណពធ្វើដំណើរ ។ លុះមាណពក្រោកឡើងហើយយាយក៏ឱ្យស្រស់ស្រូបរួចប្រគល់កញ្ចប់អាហារសំរាប់តាមផ្លូវហើយនាំបង្ហាញតម្រុយដើមឪឡឹកឱ្យចៅមាណពធ្វើដំណើរចេញទៅ ។

-នែចៅ! (យាយម៉បប្រាប់) ចូរចៅដើរទៅតាមជួរដើមឪឡឹកនេះទៅចុះ ! ចៅនិងបានទៅដល់ ផ្ទះនាងនោះហើយ តែថាចូរចៅប្រយ័ត្នខ្លួនឱ្យមែនទែនណា ! ចៅទៅចុះ ! សូមឱ្យបានសេចក្តីសុខ ឱ្យបាន សំរេច ដូចសេចក្តីប្រាថ្នាបើមាន សត្រូវមកពីមុខឱ្យរំលង បើមកពីខ្នងឱ្យរលាយណាចៅណា ។

មាណពក្រាបប្រណិប័តន៍លាលោកយាយហើយកចេញដំណើរទៅ ។ ថ្ងៃជ្រេបន្តិច ទើបទៅដល់សំណាក់ មហាចោរ ។ គាប់ជួនពេលនោះមហាចោរមិននៅ ចេញទៅរកប្លន់គេបាត់ ទុកតែកូនស្រីឱ្យនៅចាំផ្ទះ តែម្នាក់ឯង ។ នាងកំពុង តែដើរតត្រុក បោសច្រាសសម្អាតផ្ទះសម្បែងតាមទំលាប់ ពុំមានគិតក្រែងអ្វី ឡើយ ។ ឯចៅមាណពនោះទៅលបគយគន់ឃើញសព្វគ្រប់ហើយដឹងថា នាងនៅម្នាក់ឯង ក៏ប្រថុយ ស្រែកហៅ ។ នាងឮសូរមាត់មនុស្សចំលែក នឹកភ័យណាស់គិតថា "តើអ្នកណា ! ហ៊ានចូលមក ដល់ទីនេះ?" ប៉ុន្តែនាងក្រឡេកទៅឃើញយុវបុរស ជាអ្នកមានឫកពាសុភាព រាបសារល្អ មិនគួរឱ្យខ្លាច នាងក៏បើកទ្វារ ហៅឱ្យបុរសចូល ហើយនិយាយសាកសួរគ្នាទៅវិញទៅមក មិនត្រឹមតែប៉ុណ្ណោះ ក៏ទទួល រាក់ទាក់សំណេះសំណាលតាមផ្លូវលោកីយ៍ ដោយសុខចិត្តសុខកាយលើកជាស្វាមី ហើយនាំយកទៅលាក់ មិនឱ្យមហាចោរជាឪពុកដឹងឡើយ ។

ប៉ុន្តែក្នុងកាលជាបន្ទាប់មក មហាចោរសង្កេតឃើញឫកពារកូនស្រីរបស់ខ្លួនប្លែកពីធម្មតា គឺឃើញនាងតែង ខ្លួនជានិច្ចកាលធ្វើការងារសព្វសារពើក្នុងផ្ទះ ដោយមិនបាច់ឪពុកតឿនឡើយ ដូចជាចង់ផ្គាប់ផ្គន់មនុស្សណាម្នាក់ ដែលជាទីពេញចិត្ត ។ មហាចោរនឹកសង្ស័យថា "នាងនេះច្បាស់ជាមានប្រុសសហាយហើយ !" ក៏នឹកតូចចិត្តនិងកូនស្រីលាយនិងសេចក្តីខ្មាសអៀនអាសហាយនាងនោះផង ក៏ដើរចោលទីកន្លែងនោះ ទៅ ។

ឯទាំងពីរអ្នកប្តីប្រពន្ធនៅក្នុងព្រៃយូរបន្តិចទៅ មិនឃើញមហាចោរនោះត្រលប់មកវិញក៏នាំគ្នាចុះមករកភូមិស្រុក និងគេ ។ លុះមកដល់ភូមិស្រុកហើយ ក៏ចូលទៅអរគុណនិងយាយម៉ប ព្រមទាំងជូនរង្វាន់គាត់ ខ្លះទៀតផង ។

យាយម៉បមានចិត្តត្រេកអរណាស់ ដើរប្រាប់អ្នកជិតខាងឱ្យមកមើលនាង ដោយថ្លែងបូរបាច់ប្រាប់គេថា "នាងនេះមានរូបឆោមលោមពណ៌សាច់ជិតល្អ មកអំពីគេនៅតែក្នុងម្លប់ ដល់ចេញពី ម្លប់ក៏មានប្តីតែម្តង "។

អ្នកស្រុកឃើញដូច្នោះ ក៏នាំគ្នាយកកូនដែលដល់អាយុគ្រប់ការទៅឃាំងក្នុងម្លប់ដើម្បីឱ្យបានល្អដូចគេក៏ជាប់ជាទំនៀមរហូតមក ។